# សន្លឹកព័ត៌មាន

## កន្លែងលាងសម្អាតនៅកសិដ្ឋាន

ផ្ទៃយានជំនិះ និងម៉ាស៊ីនដែលប្រមូលដី និងកំទេចរុក្ខជាតិជារឿយៗ។ នេះបង្ហាញពីហានិភ័យនៃជីវសុវត្ថិភាព ពីព្រោះមានសត្វល្អិតចង្រៃនៅលើរុក្ខជាតិជាច្រើន ដូចជាបាក់តេរី ផ្សិត វីរុស វីរ៉ូអ៊ីដ សត្វអៀន និងសត្វល្អិតនានា (និងពងសត្វល្អិត) អាចនៅតែមានស្ថេរភាពនៅក្នុងដី និងរុក្ខជាតិសម្រាប់រយៈពេលយូរ។

**កន្លែងលាងសម្អាត** ជាតំបន់មួយដែលអ្នកដាំដុះ កម្មករកសិដ្ឋាន មន្ត្រីជំនួយ និងអ្នកជាប់កិច្ចសន្យា អាចលាងសម្អាត និងរម្ងាប់មេរោគពីយានជំនិះ និងម៉ាស៊ីនដែលចូលទៅក្នុង ឬចាកចេញពីតំបន់ដាំដុះ។ ការប្រើប្រាសជាប្រចាំនៃកន្លែងនឹងបន្តទៅដល់ការកាត់បន្ថយសត្វល្អិតចង្រៃចំពោះអចលនទ្រព្យ និងការរីករាលដាលដល់តំបន់នានាផ្សេងទៀត។

### ជំហានទី 1 - ការលាងសម្អាត

សម្អាតយានជំនិះ និងម៉ាស៊ីនដែលចេញ និងចូលទាំងអស់ ដោយប្រើប្រាស់ទុយោទឹកបាញ់មានសម្ពាធខ្ពស់ ឬខ្យល់បង្ហាប់ដើម្បីដកយកចេញកំទេចរុក្ខជាតិ និងដី។ ផ្តោតលើផ្នែកនានាដែលដី ឬកំទេចរុក្ខជាតិអាចជាប់ ឧ.ហ. សំបកកង់ឡាន និងធ្នូកង់។

### ជំហានទី 2 - សម្អាតសារធាតុពុល

ប្រើប្រាស់សូលុយស្យុងសម្រាប់សម្អាតសារធាតុពុលលើផ្ទៃទាំងអស់នៃយានជំនិះ កន្លែងដែលដី និងសម្ភារអាចជាប់ស្អិតលើរុក្ខជាតិ។ សូលុយស្យុងសម្រាប់សម្អាតសារធាតុពុល រួមមានភ្នាក់ងារប្រឆាំងបាក់តេរី ប្រឆាំងនឹងផ្សិត និងប្រឆាំងនឹងវីរុស ហើយត្រូវប្រើប្រាស់ទៅតាមការណែនាំស្តីដែលមាននៅលើសម្គាល់ផលិតផល។

### ជំហានទី 3 - លាងសម្អាតកន្លែងលាងសម្អាត

នៅមុនពេលផ្លាស់ទីយានជំនិះ ប្រើប្រាស់ទុយោទឹកបាញ់មានសម្ពាធខ្ពស់ នៅកន្លែងលាងសម្អាតដើម្បីធ្វើឱ្យប្រាកដថាកំទេចកំទីត្រូវបានចាប់បញ្ចូលទៅក្នុងតំបន់តំហុយ។ នៅមុនពេលផ្លាស់ទីយានជំនិះចេញពីកន្លែងលាងសម្អាត ត្រូវឱ្យកន្លែងនេះស្ងួតជាមុនសិន – ធ្វើដូចនេះនឹងបន្ថយបរិមាណកខ្វក់ដែលបានជាប់តាមសំបកកង់ឡាន។

*ការលាងសម្អាតយានជំនិះ និងម៉ាស៊ីន ជាជំហានធំមួយឆ្ពោះទៅការកាត់បន្ថយឱ្យបានជាអប្បបរមានូវការគំរាមកំហែងពីសត្វល្អិតចង្រៃដែលមាននៅលើរុក្ខជាតិ និងការគំរាមកំហែងពីជំងឺនានា។ ទោះជាយ៉ាងណាក៏ដោយ វិធានការជីវសុវត្ថិភាពមិនបញ្ចប់នៅត្រឹមតែកន្លែងលាងសម្អាតប៉ុណ្ណោះទេ។*

### នៅពេលបង្កើតកន្លែងលាងសម្អាតមួយត្រូវពិចារណាលើ...

*ទីតាំង*

ប្រើប្រាសតំបន់ដែលធំចំហរ ជិតនឹងច្រកចូលអចលនទ្រព្យ និងមានទីតាំងឆ្ងាយពីតំបន់ដាំដុះ។

*ប្រព័ន្ធបង្ហូរទឹក*

រក្សាការហូរចេញឱ្យឆ្ងាយពីច្រកចូលទៅលូបង្ហូរទឹកដើម្បីជៀសវាង ធ្វើឱ្យកខ្វក់ដល់ប្រភពទឹក។ សំណូមពរឱ្យមានតំបន់បណ្តុំរណ្តៅបង្ហូរទឹក ឬតំបន់បណ្តុំទឹកសំណល់ សម្រាប់ ប្រព័ន្ធបង្ហូរទឹក ដី និងកំទេចកំទីរុក្ខជាតិ។

*ទំហំ*

ធានាឱ្យមានកន្លែងគ្រប់គ្រាន់សម្រាប់យានជំនិះ និងម៉ាស៊ីដែលមានទំហំធំដើម្បីចូល និងផ្លាស់ទីនៅជុំវិញ។

*គ្រឿងសម្ភារសម្អាត*

ទុយោទឹកបាញ់មានសម្ពាធខ្ពស់ ឬឧបករណ៍លាងសម្អាតមានបង្ហាប់ខ្យល់ នឹងធ្វើឱ្យដំណើរការលាងសម្អាតកាន់តែមាន ប្រសិទ្ធភាព។

*ផ្ទៃ*

មានចាក់បេតុង ឬចាក់កៅស៊ូក្រាលថ្មល់គឺជាការល្អបំផុត។ ផ្ទៃមានស្មៅមិនសំណូមពរឱ្យមានទេ ដោយសារតែវាមានសក្តានុពលនាំឱ្យសត្វល្អិតចង្រៃមួយចំនួនញស់ពងនៅក្នុងដី និងមានបញ្ហាលើរុក្ខជាតិ។

*សញ្ញា*

តំបន់លាងសម្អាតត្រូវមានដាក់បង្គោលសញ្ញា និងផ្តល់ទិសដៅពី ច្រកចូលអចលនទ្រព្យទៅកាន់កន្លែងលាងសម្អាត។ ការធ្វើដូចនេះគឺដើម្បីធានាថាអ្នកចូលទស្សនាដឹងអំពីកន្លែង លាងសម្អាត និងរាយការណ៍អំពីវា នៅពេលមកដល់។



### ដំណើរការប្រព័ន្ធសម្អាតចល័តនៅលើអចលនទ្រព្យ

បង្ខាំងទុកសត្វល្អិតចង្រៃលើរុក្ខជាតិនៅគេហដ្ឋានចំពោះផ្នែកនៃអចលនទ្រព្យនឹង មានអត្ថប្រយោជន៍រយៈពេលខ្លី និងរយៈពេលយូរសម្រាប់ ការចូលប្រើប្រាស់ទីផ្សារ និងទិន្នផលផលិតកម្ម។

ដើម្បីបញ្ឈប់ការរីករាលដាលសត្វល្អិតចង្រៃពីតំបន់ដាំដុះនានា សូមប្រើប្រាស់ទុយោទឹកបាញ់ចល័តមានសម្ពាធខ្ពស់ ឬម៉ាស៊ីនបញ្ចូលខ្យល់ដើម្បីលាងសម្អាតយានជំនិះ ម៉ាស៊ីន និងគ្រឿងសម្ភារនៅមុនពេលផ្លាស់ទីទៅកាន់កន្លែងថ្មី។

Plant Health AUSTRALIA AUSVEG

សត្វល្អិតចង្រៃមិនប្រក្រតីនៅលើរុក្ខជាតិត្រូវរាយការណ៍ជាបន្ទាន់ទៅទីភ្នាក់ងារកសិកម្មដែលពាក់ព័ន្ធនៅតាមរដ្ឋ ឬដែនដីតាមខ្សែទូរសព្ទស្តីពីសត្វល្អិតចង្រៃចម្លែកលើរុក្ខជាតិតាមលេខ (1800 084 881)។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រជីវសុវត្ថិភាពនៅឯ farmbiosecurity.com.au ឬទាក់ទង AUSVEG តាមលេខ (03) 9882 0277។